ការប្រកួតប្រជែងសំណេរយុវជនសម្រាប់ព្រឹត្តិការណ៍ទិន្នន័យបើកទូលាយ ២០២០ ស្តីពី

# «តួនាទីនៃទិន្នន័យបើកទូលាយ និងព័ត៌មានក្នុងការលើកកម្ពស់តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈនៅកម្ពុជា»




## សំណេរជ័យលាភី លេខ១ ដល់ លេខ៣

ចេញផ្សាយថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០

រៀបរៀងដោយ៖

អង្គការទិន្នន័យអំពីការអភិវឌ្ឍ Open Development Cambodia

ចូលរួមសហការដោយ៖

CCIM cambodian center for independent media

តម្លាភាពកម្ពុជា TRANSPARENCY INTERNATIONAL Cambodia

# មាតិកា




០១ គុណកថា
០២ អំពីទិវាទិន្នន័យបើកទូលាយ និងការប្រកួតសំណេរ
០៣ សំណេរជ័យលាភីលេខ១
១១ សំណេរជ័យលាភីលេខ២
១៦ សំណេរជ័យលាភីលេខ៣

# គុណភកថា

អត្ថបទសំណេរចំនួនបីនេះ ជាស្នាដៃរបស់បេក្ខជនបេក្ខនារីជ័យលាភីនៃកម្មវិធីការប្រកួតប្រជែងសំណេរអត្ថបទក្នុងឱកាសទិវាទិន្នន័យបើកទូលាយឆ្នាំ២០២០ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២០។ អង្គការទិន្នន័យអំពីការអភិវឌ្ឍ ហៅកាត់ថា អូឌីស៊ី ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ អង្គការតម្លាភាពកម្ពុជា (TI Cambodia) និងមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) ដែលបានចូលរួមសហការរៀបចំ និងជាគណៈកម្មការដាក់ពិន្ទុដ៏សុក្រឹត្យសម្រាប់កម្មវិធីប្រកួតសំណេរនេះ។

**អង្គការទិន្នន័យអំពីការអភិវឌ្ឍ (ODC)** ជាមជ្ឈមណ្ឌលដែលធ្វើការនៅលើបណ្ដាញអ៊ិនធើណិត ដោយប្រមូលផ្ដុំទិន្នន័យដែលមានជាសាធារណៈ និងដោយមិនគិតថ្លៃ ដើម្បីផ្ដល់ព័ត៌មានត្រឹមត្រូវនិងថ្មីបំផុតដល់សាធារណៈជនអំពីប្រទេសកម្ពុជា ការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចរបស់ប្រទេសនេះ។

**អង្គការតម្លាភាពកម្ពុជា (TI Cambodia)** ជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកធ្វើការរួមគ្នាជាមួយបុគ្គល និងស្ថាប័នគ្រប់ជាន់ថ្នាក់ ដើម្បីលើកកម្ពស់សុចរិតភាព និងកាត់បន្ថយអំពើពុករលួយនៅក្នុងប្រទេសកម្ពុជា។

**មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)** ជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកផ្ដោតលើការលើកកម្ពស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ សេរីភាពសារព័ត៌មាន សេរីភាពបញ្ចេញមតិ ការទទួលបានព័ត៌មាន និងអភិបាលកិច្ចប្រជាធិបតេយ្យ។

**ការទទួលខុសត្រូវ៖** ទស្សនៈ យោបល់ និងការបកស្រាយដែលបានបង្ហាញនៅក្នុងការបោះពុម្ពផ្សាយនេះ គឺជាទស្សនៈរបស់បេក្ខជនប្រកួតសំណេរ ដែលជាអ្នកនិពន្ធ ហើយវាមិនគួរត្រូវបានបកស្រាយ ឬឆ្លុះបញ្ចាំងថាជាទស្សនៈផ្លូវការ ឬក្រៅផ្លូវការរបស់អង្គការទិន្នន័យអំពីការអភិវឌ្ឍ អង្គការតម្លាភាពកម្ពុជា ឬមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនោះទេ។

**រចនាក្រប និងរៀបរៀងដោយ៖** អង្គការទិន្នន័យអំពីការអភិវឌ្ឍ (ODC)

# អំពីទិន្នន័យបើកទូលាយ និងការប្រកួតសំណេរ

ទិវាទិន្នន័យបើកទូលាយឆ្នាំ ២០២០ គឺជាឱកាសមួយសម្រាប់អ្នកស្រលាញ់ចូលចិត្តទិន្នន័យបើកទូលាយដើម្បីចូលរួមសរសេរកម្មវិធី ធ្វើសេរីការទិន្នន័យ បង្កើតទស្សនីយភាពទិន្នន័យ និងផ្សព្វផ្សាយការវិភាគដោយប្រើប្រាស់ទិន្នន័យបើកទូលាយសាធារណៈ។ សកម្មភាពទាំងនេះ ត្រូវបានរៀបចំឡើងដើម្បីបង្ហាញពីអត្ថប្រយោជន៍នៃទិន្នន័យបើកទូលាយ និងដើម្បីលើកទឹកចិត្តដល់ការអនុម័តនៃគោលនយោបាយទិន្នន័យបើកទូលាយនៅក្នុងវិស័យរដ្ឋាភិបាល ធុរកិច្ច និងសង្គមស៊ីវិល។ ព្រឹត្តិការណ៍ឆ្នាំនេះ ស្ថិតក្រោមប្រធានបទ **“ទិន្នន័យបើកទូលាយសម្រាប់ការអភិវឌ្ឍដោយស្មើភាព”**។

ជាមួយនឹងប្រធានបទ **“ទិន្នន័យបើកទូលាយសម្រាប់ការអភិវឌ្ឍដោយស្មើភាព”** អូឌីស៊ីបានរៀបចំការប្រកួតប្រជែងសំណេរអត្ថបទក្រោមប្រធានបទ “**តួនាទីនៃទិន្នន័យបើកទូលាយ និងព័ត៌មានក្នុងការលើកកម្ពស់តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈនៅកម្ពុជា”** ដើម្បីលើកកម្ពស់ពីសារៈសំខាន់នៃការបើកទូលាយ និងចែកចាយទិន្នន័យ និងព័ត៌មាន រួមគ្នាជាមួយនឹងតម្រូវការដើម្បីបង្កើនការចូលរួមជាសាធារណៈកាន់តែប្រសើរ ពិសេសចូលរួមពិនិត្យការផ្តល់សេវាសាធារណៈ ដែលនឹងលើកកម្ពស់តម្លាភាព និងគណនេយ្យភាពនៅក្នុងប្រទេស។

ការប្រកួតប្រជែងនេះត្រូវបានផ្សព្វផ្សាយជាសាធារណៈ ជាពិសេសដល់យុវជនកម្ពុជា ដែលពួកគេដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្លាស់ប្តូរសង្គម កំណើនសេដ្ឋកិច្ច និងការច្នៃប្រឌិតបច្ចេកវិទ្យានៅក្នុងយុគសម័យឌីជីថលនេះ។

ឯកសារនេះចងក្រងនូវអត្ថបទសំណេរដែលបានទទួលជ័យលាភីលេខ១ លេខ២ និងលេខ៣ នៅក្នុងការប្រកួតសំណេរនៃព្រឹត្តិការ ទិន្នន័យបើកទូលាយឆ្នាំ ២០២០ នេះ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០២០*

# "តួនាទីនៃទិន្នន័យបើកទូលាយ និងព័ត៌មានក្នុងការលើកកម្ពស់តម្លាភាព និងគណនេយ្យភាព ក្នុងការផ្តល់សេវាសាធារណៈនៅកម្ពុជា"

ឃី ពិសី*

ជ័យលាភីលេខ១ ការប្រកួតសំណេរទិវាទិន្នន័យបើកទូលាយឆ្នាំ ២០២០

## សេចក្តីផ្តើម

ការបើកចំហទិន្នន័យព័ត៌មាន បាននឹងកំពុងបន្តដើរតួនាទីកាន់តែសំខាន់ខ្លាំងឡើងៗ នៃសម័យសាកលភាវូបនីយកម្មទាំងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍ។ ក្នុងនោះផងដែរទិន្នន័យត្រូវបានគេយកទៅប្រើប្រាស់នៅតាមស្ថាប័ន អង្គការ និងក្រុមហ៊ុននានា ដើម្បីបំពេញតម្រូវការទៅតាមវិស័យរៀងៗខ្លួន សូម្បីតែរដ្ឋាភិបាលនៃរដ្ឋបរទេសនីមួយៗ ក៏មានភាពចាំបាច់ត្រូវការទិន្នន័យព័ត៌មាន អំពីដំណើរការវិវឌ្ឍសង្គមរបស់ពួកគេយកមកវិភាគ តាក់តែងគោលនយោបាយសម្រាប់លើកកម្ពស់សុខុមាលភាពសង្គម និងកំណើនសេដ្ឋកិច្ចជាតិផងដែរ។ ទាំងនេះត្រូវបានគេហៅថា **"ទិន្នន័យព័ត៌មានសាធារណៈ"**។ បច្ចុប្បន្នមាន អង្គការ ស្ថាប័នមួយចំនួនបាននឹងកំពុងខិតខំបើកចំហទិន្នន័យព័ត៌មានជាច្រើន ដល់ពលរដ្ឋ និងបណ្តាអ្នកសិក្សាស្រាវជ្រាវនៅលើប្រព័ន្ធឌីជីថល។ គេហទំព័រ **អង្គការទិន្នន័យអំពីការអភិវឌ្ឍ (Open Development Cambodia)** គឺជាគេហទំព័រអង្គការសង្គមស៊ីវិល ដែលមានភាពសកម្មជាងគេទៅលើការផ្តល់ទិន្នន័យព័ត៌មានផ្សេងៗ ទៅដល់អ្នកស្វែងរកទូទៅរាប់ចាប់ពី អង្គការមួយនេះបានចុះបញ្ជីជាផ្លូវការ នៅឆ្នាំ ២០១៥ ហើយមកដល់សព្វថ្ងៃនេះ ក្រុមការងាររបស់ ODC នៅតែបន្តបេសកកម្មរបស់ខ្លួនជានិច្ច ដើម្បីជាផលប្រយោជន៍មួយសម្រាប់សាធារណៈជនដែលអាចចូលទៅមើល និងទាញយកទិន្នន័យព័ត៌មានបានយ៉ាងសេរី។

## តួនាទី និងសារៈសំខាន់នៃការទទួលបានព័ត៌មានអំពីការប្រើប្រាស់សេវាសាធារណៈ

ដើម្បីជាទុនក្នុងការពិចារណា គេអាចយល់ជាដំបូងថា៖ ទិន្នន័យព័ត៌មានសាធារណៈគឺជាបណ្តុំឯកសារដែលប្រមូលចងក្រងដោយស្ថាប័នសាធារណៈ ហើយស្ថិតក្រោមបញ្ញត្តិនៃច្បាប់ ។ ទិន្នន័យព័ត៌មានទាំងនោះមានជាអាទិ៍៖ សៀវភៅ ក្រដាសស្នាម លិខិតឯកសារ រូបថត វីឌីអូ ផែនទី គំនូរ សំឡេង រូបភាព កូដ(Code) ទិន្នន័យ(Data Source) ដែលទាំងនេះគេអាចចាត់បញ្ចូលថា ជាប្រភេទទិន្ននន័យព័ត៌មានដែលអាចប្រើប្រាស់ ទៅតាមតម្រូវការជាក់ស្តែងសម្រាប់បម្រើឱ្យប្រយោជន៍សាធារណៈ។ ទិន្នន័យព័ត៌មានបើកទូលាយអាចជួយសង្គមមួយឱ្យ សម្រេចបាននូវគោលដៅជាច្រើន។ បើតាមអង្គការសហប្រជាជាតិ ទិន្នន័យបើកទូលាយ បានចូលរួមចំណែកក្នុងគោលដៅអភិវឌ្ឍសហស្សវត្ស៍ និងគោលដៅអភិវឌ្ឍប្រកបទៅដោយចីរភាពដូចជា៖

ទី១ ៖ ជំរុញកំណើនសេដ្ឋកិច្ច និងការបង្កើតការងារ។

* **ឃី ពិសី** ជានិស្សិតច្បាប់ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

ទី២ ៖ បង្កើនប្រសិទ្ធភាព និងការគ្រប់ដណ្តប់លើសេវាសាធារណៈ។
ទី៣ ៖ បង្កើនតម្លាភាពគណនេយ្យភាព និងការចូលរួមរបស់ពលរដ្ឋ។
ទី៤ ៖ ជួយសម្រួលឱ្យមានការចែករំលែកព័ត៌មានកាន់តែប្រសើរឡើងសម្រាប់រដ្ឋាភិបាល[1]

តាមការវាយតម្លៃជាទូទៅ ទិន្នន័យព័ត៌មានពិតជាមានតួនាទីសំខាន់ ក្នុងការលើកកម្ពស់ តម្លាភាពគណនេយ្យភាព ក្នុងការផ្តល់សេវាសាធារណៈពីសំណាក់មន្ត្រីរាជការសាធារណៈនៃ រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទៅដល់ពលរដ្ឋដែលជាអ្នកប្រើប្រាស់សេវា ជាពិសេសពលរដ្ឋ អាចប្រើប្រាស់សេវាសាធារណៈប្រកបដោយទំនុកចិត្ត។ ជាថ្នូរមកវិញពលរដ្ឋបានជាប់កាតព្វកិច្ចបង់ពន្ធ ដើម្បីយកទៅបើកប្រាក់បៀវត្សរ៍ដល់មន្ត្រីរាជការដែលបម្រើសេវាដល់ពួកគាត់។

យោងលើសេចក្តីប្រកាសជាសកលរបស់អង្គការសហប្រជាជាតិ តាមរយៈអង្គការ UNESCO បានកំណត់យកថ្ងៃទី២៨ កញ្ញា ជារៀងរាល់ឆ្នាំ គឺជា **"ទិវានៃសិទ្ធិទទួលបានព័ត៌មាន"**។ ទន្ទឹមនឹងនេះរដ្ឋធម្មនុញ្ញកម្ពុជាត្រង់មាត្រា៣១ ក៏បានបញ្ជាក់ដែរថា៖ កម្ពុជាទទួលស្គាល់ពីសិទ្ធិមនុស្ស កតិកាសញ្ញារបស់អង្គការសហប្រជាជាតិ។ សិទ្ធិជាមូលដ្ឋានដែលបានចែងក្នុងលិខិតបទដ្ឋានគតិយុត្តិដូចបញ្ជាក់ជូនខាងលើ ពិតជាបានដើរតួនាទីសំខាន់ក្នុងការធានាដល់ ដំណើរការនៃការទទួលបានទិន្នន័យព័ត៌មានទៅដល់ពលរដ្ឋអំពីការប្រើប្រាស់សេវាសាធារណៈ។ សិទ្ធិទាំងនេះត្រូវបានធានាដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។[2]

ដើម្បីរៀបចំដំណើរការនេះ រដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងព័ត៌មាន បានតាក់តែងសេចក្តីព្រាងច្បាប់ "ស្តីពីសិទ្ធិទទួលបានព័ត៌មាន"[3] ក៏ប៉ុន្តែរហូតមកដល់បច្ចុប្បន្ន ច្បាប់នេះមិនទាន់បានអនុម័តនៅឡើយទេដោយកំពុងជជែកដេញដោលបន្ថែមទៀតរវាងរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ។ ច្បាប់នេះពិតជាបានដើរតួនាទីសំខាន់ព្រោះនៅពេលមានច្បាប់គាំពារ ពលរដ្ឋគ្រប់រូបនឹងអាចទទួលបាននូវទិន្នន័យព័ត៌មានផ្សេងៗ ដែលពួកគេចង់បាន ជាពិសេសព័ត៌មានពាក់ព័ន្ធនឹងវិស័យសាធារណៈ។ មិនត្រឹមតែពលរដ្ឋនោះទេ សូម្បីតែវិស័យឯកជនក៏អាចទទួលបានអត្ថប្រយោជន៍ អំពីការបើកចំហទិន្នន័យព័ត៌មាននេះផងដែរ ក្នុងនោះពួកគេអាចស្នើសុំព័ត៌មានទៅ ស្ថាប័នសាធារណៈអំពី ការគម្រោងអភិវឌ្ឍនានារបស់រដ្ឋ អាចទទួលបានព័ត៌មានផ្លូវការស្តីពីស្ថានភាព៖ សេដ្ឋកិច្ច វិនិយោគ ពន្ធដារ ច្បាប់ ជាដើម។ ចំណែកឯសង្គមស៊ីវិលពួកគេ ក៏អាចដឹងអំពីប្រសិទ្ធិភាពនៃកិច្ចការសាធារណៈ ហើយអាចលើកយកករណីណាមួយ ទៅចូលរួមពិគ្រោះផ្តល់យោបល់ក្នុងនាមជាដៃគូរអភិវឌ្ឍ ជាមួយរដ្ឋាភិបាលផងដែរ ប្រសិនបើពួកគេរកឃើញភាពមិនប្រក្រតីក្នុងការផ្តល់សេវាសាធារណៈ។

## ស្វែងយល់អំពីសេវាសាធារណៈនៅកម្ពុជា

ផ្អែមតាម **"គោលនយោបាយស្តីពី ការផ្តល់សេវាសាធារណៈ"** អនុម័តដោយគណៈរដ្ឋមន្ត្រី កាលថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៦[4] បានកំណត់ថា រាល់សកម្មភាពទាំងឡាយ ដែលធ្វើឡើងដោយ **"ស្ថាប័នមានសមត្ថកិច្ច"** និង **"ស្ថាប័នទទួលសមត្ថកិច្ច"** ក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈគឺជា **"សេវាសាធារណៈ"**។ **ស្ថាប័នមានសមត្ថកិច្ច** គឺសំដៅដល់ស្ថាប័នរដ្ឋ ភ្នាក់ងាររដ្ឋ ឬអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដែលបំពេញការងារឱ្យរាជការ។ ចំណែកឯ **ស្ថាប័នទទួលសមត្ថកិច្ច** គឺសំដៅដល់ ផ្នែកឯកជន អង្គការសង្គមស៊ីវិលដែលទទួលបានសិទ្ធិ ភារកិច្ចពីរដ្ឋ

ក្នុងការបម្រើសេវាដល់ពលរដ្ឋ ដែលស្ថិតក្រោមលក្ខន្តិកៈ និងការត្រួតពិនិត្យពីរដ្ឋ។ សេវាសាធារណៈដូចបាន កំណត់ន័យខាងលើ ត្រូវបានបែងចែក ទៅតាមវិស័យ និងការទទួលខុសត្រូវរបស់ក្រសួងស្ថាប័នជំនាញដូចខាង ក្រោមៈ

### សេវាសាធារណៈពាក់ព័ន្ធនឹងអធិបតេយ្យភាពរដ្ឋ

ក្នុងន័យនេះអង្គភាព ឬនីតិបុគ្គលរបស់រដ្ឋ គឺមាន កាតព្វកិច្ចផ្តាច់មុខក្នុងផ្តល់សេវា ទៅលើជំនាញរបស់ខ្លួន មានដូចជាៈ

- លិខិតអនុញ្ញាត អាជ្ញាប័ណ្ណ
- បញ្ជីអត្រានុកូលដ្ឋាន សៀវភៅគ្រួសារ
- ប័ណ្ណសម្គាល់យានយន្តគ្រប់ប្រភេទ អាកាសយាន្ត នាវាចរ
- វិញ្ញាបនបត្រទទួលស្គាល់កម្មសិទ្ធិ
- លិខិតបញ្ជាក់អត្តសញ្ញាណលិខិតឆ្លងដែន។ល។

### សេវាសាធារណៈពាក់ព័ន្ធនឹង ផ្នែកហេដ្ឋារចនាសម្ព័ន្ធ

មន្ទីរពេទ្យ សាលារៀន ប្រព័ន្ធទឹកស្អាត ការដឹកជញ្ជូន ថាមពលអគ្គីសនី ប្រព័ន្ធទូរគមនាគមន៍ជាដើម។ ការពិតនៅមិនទាន់អស់ សេវាសាធារណៈនៅឡើយទេ សូម្បីតែកងកម្លាំងការពារសណ្តាប់ធ្នាប់ក៏គេ ចាត់ចូលជាចង្កោមនៃសេវាសាធារណៈមួយ ដែលបម្រើពលរដ្ឋដែរ។

ការបើកចំហទិន្នន័យឬព័ត៌មានផ្សេងៗ គឺពិតជាមានសារៈសំខាន់សម្រាប់ពលរដ្ឋៈ ដោយគេអាចដឹងថា តើសេវាសាធារណៈណាខ្លះដែលបង់ថ្លៃ? ហើយបើបង់ថ្លៃ តើពលរដ្ឋត្រូវចំណាយប៉ុន្មាន? ប្រសិនបើពលរដ្ឋបានដឹង អំពីព័ត៌មាន ពួកគេអាចយល់បានថាតើឯកសាររបស់ពួក គេត្រូវប្រើពេលប៉ុន្មានដើម្បីធ្វើរួចរាល់។

## តើគណនេយ្យភាព និងតម្លាភាពក្នុងការផ្តល់សេវាសាធារណៈមានន័យដូចម្តេច ?

**គណនេយ្យភាព** គឺជាកាតព្វកិច្ចរបស់អ្នកដែល ទទួលបាននូវសិទ្ធិអំណាច ដើម្បីឆ្លើយបំភ្លឺ និងទទួលខុសត្រូវចំពោះទង្វើនានារបស់ខ្លួន ដែលកើតឡើងក្នុងសកម្មភាពពេលបំពេញការងារ។[5] ចំណែកឯ **តម្លាភាព** គឺជាការ បើកចំហរព័ត៌មានសាធារណៈ ដែលទាក់ទងនឹងការប្រជុំ គម្រោងថវិកា សវនកម្ម ការផ្តល់សេវាសាធារណៈ និងការ ធ្វើសេចក្តីសម្រេចចិត្តរបស់អ្នកតំណាងពលរដ្ឋ។ តម្លាភាព គឺជាការឆ្លុះបញ្ចាំងនូវគណនេយ្យភាព។ តម្លាភាព នៅតាមស្ថាប័ននានា គឺជាការបើកចំហរជាសាធារណៈដល់ ប្រព័ន្ធផ្សព្វផ្សាយ និងពលរដ្ឋឱ្យដឹងអំពីដំណើការនៃ សកម្មភាពការងាររបស់ខ្លួន ដោយស្តាប់នូវមតិយោបល់ ផ្សេងៗ យកមកកែលំអរប្រព័ន្ធការងារក្នុងការបម្រើសេវា សាធារណៈ ។ ក្នុងសង្គមប្រជាធិបតេយ្យកាលណាពលរដ្ឋ ទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ នោះពលរដ្ឋនឹង សកម្មក្នុងកិច្ចការសាធារណៈ ដែលធ្វើឱ្យការងារសាធារណៈរបស់មន្ត្រីរាជការប្រព្រឹត្តទៅដោយមានតម្លាភាព និង គណនេយ្យភាព ។ ក៏ប៉ុន្តែក្នុងបរិបថសង្គមយើង គេពិបាក នឹងវាយថាមានតម្លាភាព ល្អ ឬក៏អាក្រក់? ក៏ព្រោះថា ប្រសិនបើការងារប្រព្រឹត្តទៅដោយតម្លាភាពវាគឺជាឱកាស របស់ពលរដ្ឋក្នុងការចូលរួមផ្តល់យោបល់យតាមដានកិច្ចការសាធារណៈដើម្បីការពារផលប្រយោជន៍រួម។ ផ្ទុយទៅ វិញបើការផ្សព្វផ្សាយ ឬទទួលព័ត៌មាននៅមានកម្រិត ដោយទិន្នន័យរបាយការណ៍នៅមិនទាន់បើកចំហរ ប្រជាពលរដ្ឋ បុគ្គលិកស្ថាប័ន មានការលំបាកចូលទៅកាន់ ព័ត៌មាន នោះមានន័យថាវាការប្រឈមមួយដែលឈាន ទៅដល់ការដាក់ពិន្ទុទៅលើតម្លាភាព ។

**ឧទាហរណ៍ទី១** ក្រុមប្រឹក្សាឃុំ/សង្កាត់ ក្នុងតំបន់ "ក" គ្រោងនឹងផ្តល់អជ្ញាប័ណ្ណដល់ក្រុមហ៊ុនឯកជន ដើម្បីវិនិយោគក្នុងការផ្តល់ថាមពលអគ្គិសនី និងសេវាដឹកជញ្ជូនដល់ពលរដ្ឋ ដោយពុំមានការបើកឱ្យដេញថ្លៃលើគម្រោងវិនិយោគនេះនោះទេ ហើយក៏ពុំបានផ្សព្វផ្សាយដល់មហាជន ដើម្បីតាមដានការសម្រេចរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់នោះដែរ។ ក្រុមហ៊ុននោះត្រូវបានគេដឹងថាជាបក្សពួករបស់មន្ត្រីស្និទនឹងអ្នកមានអំណាចក្នុងតំបន់ "ក" ជាហេតុធ្វើឱ្យក្រុមហ៊ុនអាចតំឡើងតម្លៃសេវាស្រេចតែចិត្ត ធ្វើឱ្យពលរដ្ឋពិបាកប្រើប្រាស់សេវាយ៉ាងខ្លាំង តែដោយគ្មានជម្រើសពលរដ្ឋនៅតែស៊ូទ្រាំប្រើប្រាស់សេវាក្រុមហ៊ុននោះដដែល ។

ត្រង់ចំណុចនេះ គេអាចយល់ច្បាស់ភ្លាមថា ប្រសិនបើមាន ការបើកចំហទិន្នន័យព័ត៌មានអំពីការអនុវត្តមុខងារសាធារណៈឱ្យបានទូលាយ នោះរាល់អំពើពុករលួយ នឹងត្រូវបានកាត់បន្ថយជាសត្យានុម័ត ព្រោះទិន្នន័យព័ត៌មានគឺជាឧបករណ៍ដ៏សំខាន់មួយ ដើម្បីបើកបង្ហាញនូវតម្លាភាព សម្រាប់លើកកម្ពស់នូវអភិបាលកិច្ចល្អ និងប្រឆាំងនឹងអំពើពុករលួយ ជាពិសេសស បង្កើនប្រសិទ្ធភាពបំពេញមុខងាររបស់មន្ត្រីរាជការ ក្នុងការផ្តល់សេវាសាធារណៈជូនដល់ពលរដ្ឋ។

ការបើកទូលាយនូវទិន្នន័យព័ត៌មាន គឺជាកត្តាជួយជំរុញឱ្យមានការអភិវឌ្ឍ ព្រោះថាទិន្នន័យផ្សេងៗរបស់ស្ថាបន័សាធារណៈត្រូវបានតាមដាន និងវាយតម្លៃពីពលរដ្ឋ ក្នុងនោះក៏បង្ករឱ្យមានភាពងាយស្រួលក្នុងការរៀបចំគោលនយោបាយសម្រាប់ការផ្តល់សេវាសាធារណៈផងដែរ ។ ពាក់ព័ន្ធនឹងបញ្ហានេះដែរ កាលពីឆ្នាំ ២០១៦ ក្រសួងមហាផ្ទៃបានចុះហត្ថលេខាលើអនុស្សារណៈយោគយល់មួយក្នុង **ទំហំទឹកប្រាក់ ១៣លានដុល្លារ សម្រាប់ រយៈពេល៣ឆ្នាំ ស្តីពី "ផែនការអនុវត្តគណនេយ្យភាពសង្គម"** ដើម្បីពង្រឹងទំនាក់ទំនងរវាងពលរដ្ឋជាអ្នកទទួលសេវា និងមន្ត្រីរដ្ឋាភិបាលមូលដ្ឋាន ដែលជាអ្នកផ្តល់សេវា។[6] ផែនការគណនេយ្យភាពនេះ ក៏នឹងជម្រុញឱ្យមន្ត្រីមូលដ្ឋានផ្តល់សេវាដែលមានគុណភាព ព្រមទាំងផ្សព្វផ្សាយអំពីតម្លាភាពថវិកា ដល់ពលរដ្ឋនៅក្នុងតំបន់របស់ខ្លួនផងដែរ ។

តម្លាភាព មិនត្រឹមតែជាការឆ្លុះបញ្ចាំងនូវ គណនេយ្យភាព និងការចូលរួមពីពលរដ្ឋប៉ុណ្ណោះទេ ថែមទាំងផ្តល់នូវការអភិវឌ្ឍមានលក្ខណៈប្រាកដប្រជាច្បាស់លាស់ ដោយពលរដ្ឋទទួលបានផលប្រយោជន៍ស្មើៗគ្នា។ ការធ្វើបែបនេះនឹងធ្វើឱ្យ កម្រិតជីវភាពរបស់ពលរដ្ឋមានភាពងាយស្រួលក្នុងការប្រើប្រាស់សេវាសាធារណៈ។ តម្លាភាពអាចទប់ស្កាត់អំពើពុករលួយ ព្រោះរាល់សកម្មភាពសំខាន់ៗ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ។ តម្លាភាព ប្រៀបដូចជា កាមេរ៉ាថតសកម្មភាពនានារបស់មន្ត្រីសាធារណៈ ហើយសកម្មភាពទាំងនេះ នឹងត្រូវបានពិនិត្យវាយតម្លៃពីពលរដ្ឋរាប់លាននាក់។ ការនេះ គេអាចឆ្លុះបញ្ចាំងទៅដល់ការដឹកនាំរបស់រដ្ឋបាលថ្នាក់ជាតិ ដែលគ្រប់គ្រងដោយគណបក្សនយោបាយ ប្រសិនបើអ្នកនយោបាយដឹកនាំរដ្ឋ គ្មានប្រសិទ្ធិភាពទៅលើកិច្ចការសាធារណៈនោះគណបក្សនយោបាយរបស់ខ្លួន អាចនឹងបាត់បង់សម្លេងគាំទ្រពីពលរដ្ឋ។

ដើម្បីឆ្លុះបញ្ចាំងដល់កម្រិតតម្លាភាព ក្នុងបរិបថនៃសង្គមកម្ពុជាជាក់ច្បាស់ គេអាចមើលរបាយការណ៍របស់អង្គការតម្លាភាពអន្តរជាតិដែលបានចាត់ថ្នាក់កម្ពុជា **ជាប់លេខ១៦១** ក្នុងចំណោម ១៨០ប្រទេសដែលមានអំពើពុករលួយខ្លាំងនិងបានទទួលពិន្ទុទាបបំផុតនៅអាស៊ាន។[7]

## បញ្ហាប្រឈមក្នុងការទទួលបាននូវទិន្នន័យព័ត៌មានអំពីសេវាសាធារណៈ

នៅកម្ពុជាតម្រូវការព័ត៌មានរបស់ពលរដ្ឋជាទូទៅ គឺមិនទាន់មាននោះទេ "ដោយសារតែកង្វះខាតនៃការយល់ដឹងអំពីសិទ្ធិ និងការស្ទាក់ស្ទើរក្នុងការស្នើសុំព័ត៌មាន ។ ប្រសិនបើពលរដ្ឋចង់ដឹងព័ត៌មានច្រើនអំពីកិច្ចការសាធារណៈ ពួកគេអាចនឹងរងការចោទប្រកាន់ ឬលាបពណ៌ថា ជាបក្សប្រឆាំងតាមរយៈការជ្រៀតជ្រែកការងារមន្ត្រីរាជការ។[៨] តាមរយៈសេចក្តីថ្លែងការណ៍រួម របស់ក្រុមអង្គការសង្គមស៊ីវិលកាល ពីខែកញ្ញា ឆ្នាំ២០១៩ បានអះអាងថាបច្ចុប្បន្ននេះប្រជាជនកម្ពុជា ពុំទាន់មានសិទ្ធិពេញលេញទទួលបាននូវព័ត៌មាន សាធារណៈដែលធានាដោយច្បាប់នោះទេ[៩] បើទោះបីជាកម្ពុជាមានច្បាប់មួយចំនួនដូចជា៖ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានកំណត់អំពីតួនាទីនិងការទទួលខុសត្រូវរបស់រដ្ឋបាល ថ្នាក់ក្រោមជាតិក្នុងការបើកចំហរ និងផ្សព្វផ្សាយព័ត៌មាន ទៅដល់ពលរដ្ឋរបស់ខ្លួននៅតាមមូលដ្ឋានក៏ដោយ តែការអនុវត្តជាក់ស្តែងគឺពុំបានទូលំទូលាយ។

ជាគោលការណ៍អង្គភាពសាធារណៈ ត្រូវជាប់កាតព្វកិច្ចដើម្បីបង្ហាញទិន្នន័យព័ត៌មានដែលពាក់ព័ន្ធនឹងប្រយោជន៍សាធារណៈទៅដល់ពលរដ្ឋ បណ្តាអង្គភាព ស្ថាប័នទាំងអស់ ទាំងឯកជន និងសង្គមស៊ីវិល តាមតម្រូវការបន្ទាប់ពីស្នើសុំ ឬពុំមានការស្នើសុំក្តី។ ប៉ុន្តែភាពជាក់ស្តែងការអនុវត្តបែរជាពុំដូចអ្វីដែលមានក្នុងក្រដាស់នោះឡើយ ដោយពេលខ្លះមន្ត្រីកាន់ការនេះបែរជាមានហេតុផលបិទបាំងដោយអះអាងថាជាព័ត៌មានសម្ងាត់ទៅវិញ ទោះបីជាព័ត៌មានទាំងនោះជាទិន្នន័យសាធារណៈដែលពាក់ព័ន្ធនឹងការប្រើប្រាស់សេវារបស់ពលរដ្ឋក៏ដោយ ។

## ដំណោះស្រាយ

ផ្អែកលើប្រតិបត្តិការល្អពីប្រទេសផ្សេងៗ ក្នុងនាមជាយុវជន យើងស្នើឱ្យមានយន្តការបន្ថែមទៀត ដើម្បីជំរុញដល់សិទ្ធិទទួលបាននូវទិន្នន័យព័ត៌មានបើកទូលាយ ដើម្បីលើកកម្ពស់ តម្លាភាពគណនេយ្យភាពសង្គមតារយៈដំណោះស្រាយដូចខាងក្រោម៖

- **ត្រូវបើកចំហរទិន្នន័យព័ត៌មាន៖** ទាំងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គប្បីបើកទូលាយនូវព័ត៌មានផ្សេងៗដល់ពលរដ្ឋ ដែលពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈឱ្យបានអតិបរមា។
- **គោរពកាតព្វកិច្ច** ៖ ស្ថាប័នសាធារណៈ ត្រូវតែចូលរួមជំរុញ និងមានកាព្វកិច្ចលើកស្ទួយឱ្យសកម្មក្នុងការផ្សព្វផ្សាយ តាមគ្រប់មធ្យោបាយផ្សេងៗ ដែលស្របតាមបរិបទ ដើម្បីឱ្យព័ត៌មានពាក់ព័ន្ធនឹងសេវាសាធារណៈទៅដល់ពលរដ្ឋនៃការប្រើប្រាស់សេវា ទីតាំងផ្តល់សេវា តម្លៃសេវានៅតាមការិយាលល័យ ផ្តល់ព័ត៌មានតាមក្រសួងមន្ទីរដែលធ្វើការលើវិស័យ ជំនាញរបស់ខ្លួន ដោយត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ នូវទិន្នន័យព័ត៌មាននៃសេវាកម្មសាធារណៈទាំងនោះ។
- **ត្រូវសម្របសម្រួលក្នុងការផ្តល់ទិន្នន័យព័ត៌មាន៖** រាល់សំណុំព័ត៌មានទាំងឡាយណា ដែលត្រូវបានក្រុមអ្នកសារព័ត៌មាន អង្គការសង្គមស៊ីវិល និងពលរដ្ឋស្នើសុំ គប្បីឆ្លើយតបឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ប្រកបដោយតម្លាភាព ដោយកំណត់រយៈពេលរង់ចាំនៃការឆ្លើយតបឱ្យបានច្បាស់លាស់។ ក្នុងករណីមន្ត្រីសាធារណៈបដិសេធមិនផ្តល់ព័ត៌មាន ត្រូវបញ្ជាក់មូលហេតុ ឱ្យបានច្បាស់ជាលាយលក្ខណ៍អក្សរ ក្នុងនោះក៏ត្រូវមានគណៈកម្មការ ឬយន្តការដើម្បីពិនិត្យមើលដោយឯករាជ្យលើករណីនេះផងដែរ។

• **ករណីបង់ថ្លៃស្នើសុំព័ត៌មានៈ** រាល់គ្រប់ទម្រង់នៃការស្នើសុំព័ត៌មាន ដែលជាផលប្រយោជន៍សាធារណៈ ឬបម្រើឱ្យសេវាសាធារណៈ មិនគួរគិតបញ្ចូលជាតម្លៃបង់ថ្លៃឡើយ ។

• **ត្រូវលើកទឹកចិត្តចំពោះការផ្តល់ព័ត៌មានៈ** រាល់ស្ថាប័ន ឬបុគ្គលដែលផ្តល់ទិន្នន័យព័ត៌មាន អំពីទិន្នន័យសាធារណៈគប្បីត្រូវបានលើកទឹកចិត្ត និងគាំពារ ។

• **បង្កលក្ខណៈងាយស្រួលៈ** គ្រប់អង្គភាពស្ថាប័នរបស់រដ្ឋត្រូវបង្កភាពងាយស្រួលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការផ្តល់ទិន្នន័យព័ត៌មានទៅដល់សាធារណៈជនដោយគ្មានការរើសអើងអ្វីទាំងអស់។ ការបង្ហាញទិន្នន័យនៅលើគេហទំព័រវេបសាយ ឬទំព័រហ្វេសប៊ុកផេកបណ្តាញសង្គមក៏ជាការបង្ករលក្ខណៈងាយស្រួលដល់អ្នកប្រើប្រាស់សេវាផងដែរ។ ផ្អែកតាមរបាយការណ៍របស់ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ CCIM បានបង្ហាញថាអ្នកប្រើប្រាស់អ៊ីនធើណេតនៅកម្ពុជាកំឡុងឆ្នាំ ២០១៥ មានចំនួន ៥២% ស្មើនឹងចំនួនប្រជាជន ៣,៨ លាននាក់[10] ដូចនេះហាក់ដូចជា មិនពិបាកសោះឡើយ សម្រាប់រដ្ឋាភិបាលក្នុងការផ្សព្វផ្សាយទិន្នន័យព័ត៌មាន ដែលពាក់ព័ន្ធនឹងការប្រើប្រាស់សេវាសាធារណៈរបស់រដ្ឋទៅក្នុងប្រព័ន្ធឌីជីថល ដើម្បីឱ្យអ្នកទស្សនាអាចចូលទៅមើល និងទាយយកបានដោយសេរី និងគ្រប់ពេល ។

• **ត្រូវពង្រឹងអភិបាលកិច្ចល្អ** ទាំងក្នុងវិស័យ សាធារណៈ និងវិស័យឯកជន។ ការពង្រឹងអភិបាលកិច្ច គឺជាកាតព្វកិច្ចរបស់រដ្ឋាភិបាលក្នុងការផ្តល់សេវាសាធាណៈ ទៅដល់ពលរដ្ឋ ព្រោះនៅក្នុងគោលការណ៍នៃអភិបាលកិច្ចល្អ ក៏មានផងដែរគោលការណ៍ដែលឆ្លើយតបឱ្យមានប្រសិទ្ធិភាពចំពោះសេចក្តីស្នើ និងក្តីកង្វល់របស់ពលរដ្ឋដោយកាត់បន្ថយឱ្យបានទាបនូវតម្លៃ នៃការប្រើប្រាស់សេវារបស់រដ្ឋ។ ការផ្តល់សេវាសាធារណៈគ្រប់ប្រភេទ ទោះតាមយន្តការ ទីកន្លែង ឬកាលៈទេសៈណាក៏ដោយ រដ្ឋត្រូវគិតដល់លទ្ធភាពចំពោះដល់ជនក្រីក្រ។ ត្រូវរុញភ្នាក់ងារនៃការផ្តល់សេវា ទៅដល់មូលដ្ឋានដែលជិតនឹងពលរដ្ឋបំផុត។ ចំពោះសេវាសាធារណៈណាដែលរដ្ឋបាលសាធារណៈ ពុំទាន់មានលទ្ធភាពផ្តល់ជូនអ្នកប្រើប្រាស់បានរដ្ឋអាចស្វែងរកដៃគូអភិវឌ្ឍដែលមានលទ្ធភាពដើម្បីជួយសម្រួលដល់តម្រូវការពលរដ្ឋ ។

• **កាត់បន្ថយរាល់បែបបទស្មុគស្មាញ** និងវែងវង្វេងនៅតាមអង្គភាពស្ថាប័នរដ្ឋ និងភ្នាក់ងារឯកជនដែលទទួលបានអាជ្ញាប័ណ្ណពីរដ្ឋ ក្នុងការបម្រើសេវាសាធារណៈ ។

• **បំបាត់ចោលនូវភារកិច្ចជាន់គ្នារបស់អង្គភាពពាក់ព័ន្ធនានារបស់រដ្ឋ** ដើម្បីជំរុញដំណើរការត្រួតពិនិត្យមានតែកន្លែងមួយ តាមរយៈការពង្រឹងនូវយន្តការ "ច្រកចេញចូលតែមួយ"។

• **ត្រូវមានតម្លាភាព និងការទទួលខុសត្រូវក្នុងការផ្តល់សេវាៈ** អ្នកផ្តល់សេវាទាំងរដ្ឋ និងឯកជន ត្រូវផ្តល់ព័ត៌មានឱ្យបានទូលំទូលាយ ជាចំហដោយគ្មានការរើសអើង និងយកចិត្តទុកដាក់ផ្តល់សេវាឱ្យបានទាន់ពេលវេលាកំណត់ ប្រកបដោយគុណភាពជូនអ្នកប្រើប្រាស់។ ទន្ទឹមនឹងនេះ អ្នកផ្តល់សេវាក៏ត្រូវទុកលទ្ធភាពឱ្យអ្នកប្រើប្រាស់សេវាតាមដាន និងស្វែងយល់អំពីនីតិវិធីនៃការផ្តល់សេវាផងដែរ ជាពិសេសគឺអ្នកទទួលសេវាអាចទិតៀនតវ៉ា ឬទាមទារឱ្យមានការកែលំអរចំណុចខ្វះខាតផ្សេងៗ តាមតម្រូវការសំដៅលើកកម្ពស់ប្រសិទ្ធភាព និងតម្លាភាពស្របតាមគោលការណ៍អភិបាលកិច្ចល្អ។

• **វិធានការណ៍ច្បាប់ៈ** ត្រូវផ្តន្ទាទោសដល់បុគ្គលណាដែលមានការកិច្ចផ្តល់ទិន្នន័យព័ត៌មាន តែបែជាលាក់បាំងព័ត៌មាន ឬមានចេតនាទាមទារនូវផលប្រយោជន៍

ណាមួយដោយត្រូវផ្តន្ទាទោសបុគ្គលនោះទៅតាមផ្លូវច្បាប់ជាធរមាន តាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ។[11]

- **ករណីវិវាទ៖** ក្នុងករណីមានវិវាទពាក់ព័ន្ធនឹងការប្រើប្រាស់សេវាសាធារណៈដោយមានវិវាទរវាងពលរដ្ឋ និង ពលរដ្ឋ ឬពលរដ្ឋនិងរាជការ ឬរវាងពលរដ្ឋ និងវិស័យឯកជនជាដើម ការដោះស្រាយត្រូវធ្វើតាមរូបភាពពីរយ៉ាង ៖

**ទី១ តាមរយៈក្រុមប្រឹក្សាអាជ្ញាកណ្តាល** ដែលជាអ្នកសម្របសម្រួលដោះស្រាយវិវាទកម្រិតស្រាល ដើម្បីសម្រួលដល់ភាគី ដោយមិនចាំបាច់ពឹងលើតុលាការ និងកាត់បន្ថយការកកស្ទះសំណុំរឿង។

**ទី២ ប្រសិនបើគូភាគីមិនយល់ស្រប** ទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ នោះគេអាចប្តឹងទៅតុលាការរដ្ឋបាលបាន។

រាល់ចំណុចដូចបានបញ្ជាក់ខាងលើគឺជាដំណោះស្រាយដែលអាចធ្វើបាន ដោយឆ្លងកាត់ការសិក្សា និងមានភាពប្រាកដប្រជា។

**ដើម្បីសម្រេចបាននូវដំណោះស្រាយខាងលើបានគេត្រូវមានវិធីសាស្ត្រដូចខាងក្រោម៖**

❖ **<u>ផ្លាស់ប្តូរអាកប្បកិរិយា និងទម្លាប់ការងាររបស់អ្នកផ្តល់សេវា</u>**

នេះជាចំណុចគន្លឹះ ព្រោះថា បើទោះបីជារបៀបរបប និងនីតិវិធីនៃការអនុវត្តល្អយ៉ាងណាក៏ដោយ តែបើមន្ត្រីឬភ្នាក់ងារឯកជន ដែលជាអ្នកផ្តល់សេវាមិនធ្វើការផ្លាស់ប្តូរឥរិយាបថរបស់ខ្លួនទេ នោះគេក៏មិនរំពឹងថាអ្នកទទួលសេវា អាចទទួលបាននូវអ្វីដែលពួកគេចង់បានប្រកប ដោយគុណភាពដែរ ។ គេត្រូវការពេលវេលា និងឆន្ទៈពីរដ្ឋាភិបាលទាំងមូលដើម្បីកែប្រែទស្សនៈពី **"អ្នកគ្រប់គ្រង"** មកជាអ្នក **"ផ្តល់សេវា"** ។

❖ **<u>កែប្រែរបៀបរបប "វចនាសម្ព័ន្ធការងារមុខងារ" ទៅជា "វចនាសម្ព័ន្ធប្រតិបត្តិការ"</u>**

**វចនាសម្ព័ន្ធមុខងារ** គឺសំដៅដល់ការងារមួយដែលតែងធ្វើទៅតាមនីតិវិធី និងបទប្បញ្ញត្តិដែលបានកំណត់ ដោយមិនគិតពីលទ្ធផល ប្រសិទ្ធភាព និងការពេញចិត្តរបស់អ្នកប្រើប្រាស់សេវាឡើយ។ **វចនាសម្ព័ន្ធប្រតិបត្តិការ** គឺបែបបទថ្មីដោយអនុវត្តទៅតាមទស្សនទានពីរ៖ ជួរមុខ និងជួរក្រោយ។ ជួរមុខ គឺជាផ្នែកទំនាក់ទំនងដោយផ្ទាល់ជាមួយអ្នកប្រើប្រាស់សេវា ដោយផ្នែកនេះគឺជាការប្រឹក្សាយោបល់ផ្តល់ព័ត៌មាន ពន្យល់អំពីនីតិវិធីនៃការទទួលសេវាបញ្ជូននិងបែងចែកឯកសារទៅតាមវិស័យជំនាញទៅដល់ជួរខាងក្រោយ។ ចំណុចដែលបានលើកឡើងខាងលើសុទ្ធតែជាចំណុចអាទិភាពដែលអាចធ្វើបានរដ្ឋាភិបាលអាចយកចំណុចទាំងនេះទៅពិចារណា និងអនុវត្ត ដោយអាចរៀបចំចែងជាសារាចរណ៍ណែនាំ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ។

## សន្និដ្ឋាន

ឆ្លងតាមការស្រាយបញ្ជាក់តាមបែបតក្ក ដូចបានជម្រាបជូនខាងលើមកគេអាចសន្និដ្ឋានជារួមថា៖ ទិន្នន័យព័ត៌មានបើកទូលាយ អាចជួយសង្គមមួយឱ្យសម្រេចបាននូវគោលដៅជាច្រើន ជាពិសេសអាចលើកកម្ពស់ តម្លាភាព គណនេយ្យភាព ក្នុងការផ្តល់សេវាសាធារណៈពីសំណាក់មន្ត្រីរាជការសាធារណៈនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទៅដល់ពលរដ្ឋដោយពួកគេ អាចប្រើប្រាស់សេវាសាធារណៈប្រកបដោយទំនុកចិត្ត។ ទោះបីយ៉ាងនេះក្តីការគេចាំបាច់ត្រូវធ្វើកំណែទម្រង់ និង បង្កើននូវកិច្ចសហការជាដៃគូជាមួយស្ថាប័នផ្សេងៗ មានអង្គការសង្គមស៊ីវិល ឬអង្គភាពនានាដែលចំណុះឱ្យ

រដ្ឋាភិបាលផងដែរ ដើម្បីបើកឱ្យមានការទទួលបានទិន្នន័យព័ត៌មានអំពី ការប្រើប្រាស់សេវាសាធារណៈកាន់តែ ធំជាងពេលបច្ចុប្បន្ន។ ប្រជាជនកម្ពុជាមិនអាចដើរតួនាទីសកម្មក្នុងសង្គមបានឡើយ ប្រសិនបើគេមិនបានទទួលព័ត៌មានត្រឹមត្រូវនិងគ្រប់គ្រាន់ទៅលើការប្រើប្រាស់សេវាសាធារណៈ ដែលរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបម្រើជូនពលរដ្ឋនោះ៕

## ឯកសារពិគ្រោះយោបល់

---

[1] Cambodia CICT Camp 2018 – Open Data for Sustainable Development ចុះផ្សាយដោយយូធូប អង្គការទិន្នន័យអំពីការអភិវឌ្ឍកម្ពុជា ថ្ងៃទី២ កក្កដា ២០១៩ https://www.youtube.com/watch?v=Z0DOm-zsbow

[2] "កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ"  អនុម័តដោយអង្គការសហប្រជាជាតិនៅថ្ងៃទី១៦ ធ្នូ ១៩៦៦ ចុះផ្សាយបន្តដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា http://www.sithi.org/admin/upload/law/section_01_03_KHM.pdf

[3] "ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន" ចុះផ្សាយដោយក្រសួងព័ត៌មាន នៅឆ្នាំ២០០៦ http://a2i.info.gov.kh/html/law.php

[4] ទំព័រទី៦ "គោលនយោបាយស្តីពី ការផ្តល់សេវាសាធារណៈ" អនុម័តដោយគណៈរដ្ឋមន្ត្រី ថ្ងៃទី៥ ឧសភា ២០០៦ http://a2i.info.gov.kh/html/law.php

[5] ទំព័រទី៧ "តួនាទីភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងករណីយកិច្ចរបស់ពលរដ្ឋ ក្នុងការលើកកម្ពស់គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ" ចុះផ្សាយដោយវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ" ពុំដឹងឆ្នាំបោះពុម្ព http://ticambodia.org/library/wp-content/files_mf/1452241106api_2011_0v2.pdf

[6] ហ៊ាន សុជាតា "រដ្ឋាភិបាល នឹងពង្រឹងគណនេយ្យភាពសង្គម" ចុះផ្សាយដោយគេហទំព័រសម្លេងសហរដ្ឋអាមេ   រិក នៅថ្ងៃទី០៥ ធ្នូ ២០១៦ https://khmer.voanews.com/a/government-to-enforce-social-accountability-using-13-million-dollars-for-the-next-three-years/3623278.html

[7] ហ៊ុល រស្មី "កម្ពុជានៅតែជាប្រទេសពុករលួយបំផុត" ចុះផ្សាយដោយគេហទំព័រសម្លេងសហរដ្ឋអាមេរិក នៅថ្ងៃទី២៩ មករា ២០១៩ https://khmer.voanews.com/a/cambodia-remains-one-of-the-most-corrupted-countries-a-report-says/4763495.html

[8] ទំព័រ ១៨ "សេរីភាពខាងព័ត៌មាននៅកម្ពុជា៖ សិទ្ធិយល់ដឹង ឬវប្បធម៌នៃការលាំងបាំង" ចុះផ្សាយដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ឆ្នាំ២០១២ http://ticambodia.org/library/wp-content/files_mf/1438607810Report_Freedom_of_Information_in_Cambodia_A_right_to_know_or_a_culture_of_secrecy_KHM.pdf

[9] រ៉ា សំណព្វ "ទិវាសិទ្ធិទទួលព័ត៌មានជាសកល" ដោយ វិទ្យុបារាំងអន្តរជាតិ ចុះផ្សាយថ្ងៃទី១៨ កញ្ញា ២០១៩ http://www.rfi.fr/km/cambodia/desk-somnop-NGO-Press-Law-28-09-2019

[10] ទំព័រទី២ "របាយការណ៍សង្ខេបនៃការស្រាវជ្រាវអំពីសេរីភាពបញ្ចេញមតិលើប្រព័ន្ធព័ត៌មានវិទ្យា និងការចូលរួមនយោបាយនៅកម្ពុជា" ចុះផ្សាយដោយមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ CCIM នៅឆ្នាំ២០១៥ http://ticambodia.org/library/wp-content/files_mf/1449214218Research_Brief_KH.pdf

[11] មាត្រា៣៣ "ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ" អង្គភាពប្រឆាំងអំពើពុករលួយ  នៅថ្ងៃទី១១ មីនា ២០១០ http://www.acu.gov.kh/kh_sub_index.php?4a8a08f09d37b73795649038408b5f33=2&03c7c0ace395d80182db07ae2c30f034=10&9e3669d19b675bd57058fd4664205d2a=8

*រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០២០*

# "តួនាទីនៃទិន្នន័យបើកទូលាយ និងព័ត៌មានក្នុងការលើកកម្ពស់តម្លាភាព និងគណនេយ្យភាព ក្នុងការផ្តល់សេវាសាធារណៈនៅកម្ពុជា"

ខេង រដ្ឋា*

ជ័យលាភីលេខ២ ការប្រកួតសំណេរទិវាទិន្នន័យបើកទូលាយឆ្នាំ ២០២០

ក្រោយការបញ្ចប់សង្គ្រាមស៊ីវិល កម្ពុជាបាននិងកំពុងខិតខំយ៉ាងសស្រាក់សស្រាំក្នុងការអភិវឌ្ឍខ្លួន ដើម្បីឆ្លើយតបនឹងនិន្នាការ ក៏ដូចជាការប្រកួតប្រជែងក្នុងតំបន់ និងសកលលោកទាំងមូល។ ការកសាងហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍធនធានមនុស្ស និងកំណើនសេដ្ឋកិច្ចគឺជាឧទាហរណ៍ជាក់ស្តែងមួយចំនួន អំពីភាពរីកចម្រើនរបស់កម្ពុជា។ ការពង្រឹងប្រព័ន្ធអភិបាលកិច្ច រួមទាំងកំណែទម្រង់រដ្ឋបាលសាធារណៈក៏ជាការងារអាទិភាពមួយដែលកម្ពុជាបាន និងកំពុងប្តេជ្ញាចិត្តផងដែរ។[1,2] វិស័យបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង(ICT) បានក្លាយជាឧបករណ៍ដ៏សំខាន់សម្រាប់កម្ពុជា និងប្រទេសផ្សេងទៀត ដើម្បីគាំទ្រការអនុវត្តកំណែទម្រង់វិស័យសាធារណៈ ព្រមទាំងយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិទាំងមូល។ ដោយឡែកគោលគំនិតស្តីពី ទិន្នន័យបើកទូលាយ និងព័ត៌មាន គឺជាទំនោរថ្មីមួយ ដែលប្រទេសជាច្រើនចាប់ផ្តើមអនុវត្ត ដើម្បីឱ្យកាន់តែងាយស្រួលក្នុងការកែលម្អអភិបាលកិច្ច ការផ្តល់សេវាសាធារណៈ និងជំរុញសុខុមាលភាពប្រជាពលរដ្ឋ។ តើទិន្នន័យបើកទូលាយ និងព័ត៌មានដើរតួនាទីយ៉ាងដូចម្តេចក្នុងការលើកកម្ពស់តម្លាភាព និងគណនេយ្យភាពនៃការផ្តល់សេវាសាធារណៈនៅកម្ពុជា? ពាក់ព័ន្ធនឹងប្រធានបទនេះ តើប្រទេសកម្ពុជាបច្ចុប្បន្នស្ថិតក្នុងបរិបទបែបណា? ហើយភាគីពាក់ព័ន្ធនានាអាចធ្វើអ្វីបានខ្លះដើម្បីឆ្លើយតបនឹងឧបសគ្គទាំងដំបូង ខ្ញុំសូមទាញចំណាប់អារម្មណ៍លោកអ្នក មកស្វែងយល់នូវគោលគំនិត "ទិន្នន័យបើកទូលាយ" ជាមុនសិន។ ទិន្នន័យបើកទូលាយ គឺជាទិន្នន័យទាំងឡាយណាដែលត្រូវបានប្រមូលផ្តុំសម្រាប់ប្រយោជន៍ សាធារណៈ គួរតែដាក់ឱ្យប្រើប្រាស់ជាសាធារណៈ ពោលគឺដោយគ្មានការដាក់កំហិតឡើយ។[3] ទិន្នន័យបើកទូលាយ សំដៅលើទិន្នន័យ ឬព័ត៌មានដែលត្រូវបានបង្ហោះនៅលើអ៊ីនធឺណិតសម្រាប់មនុស្សគ្រប់គ្នាប្រើប្រាស់ ឬបោះផ្សាយឡើងវិញក្នុងគោលបំណងផ្សេងៗ។ ក្នុងករណីភាគច្រើន វាស្ថិតក្នុងទម្រង់ដែលម៉ាស៊ីនអាចអានបាន (machine-readable format) ថែមទាំងងាយយល់។[4] ព័ត៌មាន និងទិន្នន័យបើកទូលាយដើរតួនាទីយ៉ាងសំខាន់ ក្នុងការលើកកម្ពស់តម្លាភាព និងគណនេយ្យភាពនៃការផ្តល់សេវាសាធារណៈ។ សម្រាប់ប្រជាពលរដ្ឋទូទៅ ព័ត៌មាន និងទិន្នន័យបើកទូលាយ គឺជាឧបករណ៍ចំណេះដឹង។ វាជួយឱ្យពួកគេទទួលបានព័ត៌មាននានាដែលពួកគេត្រូវការ ពាក់ព័ន្ធនឹងសេវាសាធារណៈ ជាពិសេសសេវាសុខភាព អប់រំ និងសេវារដ្ឋបាលមូលដ្ឋានជាដើម។ ព័ត៌មាន និងទិន្នន័យទាំងនោះជួយប្រជាពលរដ្ឋកាត់បន្ថយការខ្ជះខ្ជាយពេលវេលា ការចំណាយដែលមិនចាំបាច់ និងហានិភ័យផ្សេងទៀត។ តួយ៉ាង ការទទួលព័ត៌មាន ឬទិន្នន័យអំពីគ្រឹះស្ថាន

* **ខេង រដ្ឋា** ជាជំនួយការផ្នែកស្រាវជ្រាវ និងតស៊ូមតិនៅអង្គការតម្លាភាពកម្ពុជា។

សុខាភិបាល ជំនាញឯកទេសនៃគ្រឹះស្ថាននីមួយៗ ម៉ោងរដ្ឋបាល ទីតាំង តម្លៃ នីតិវិធីដើម្បីទទួលបានសេវា ឬការទទួលបានព័ត៌មានទូទៅអំពីការគាំពារខ្លួនពីជំងឺ ឬមេរោគឆ្លងអ្វីមួយ។ល។ ដែលទិន្នន័យ និងព័ត៌មានទាំងនោះ ពិតជាជួយឱ្យពួកគេ ស្វែងរកសេវាសុខភាពដែលសាកសម លើកកម្ពស់សុខុមាលភាព និងកាត់បន្ថយហានិភ័យគ្រោះថ្នាក់ដល់អាយុជីវិត។ ស្រដៀងគ្នាដែរ ការទទួលបានព័ត៌មាន ឬទិន្នន័យនានាអំពីគ្រឹះស្ថានអប់រំ នឹងជួយឱ្យអាណាព្យាបាលបញ្ជូនកូនទៅសិក្សាចំគោលដៅ និងមានប្រសិទ្ធភាព។ ក្រៅអំពីការដើរតួនាទីជាឧបករណ៍ចំណេះដឹង ព័ត៌មាន និងទិន្នន័យបើកទូលាយក៏រួមចំណែកលើកទឹកចិត្តសាធារណជនឱ្យចូលរួមជាមួយរដ្ឋាភិបាលក្នុងការលើកកម្ពស់គុណភាព តម្លាភាព និងគណនេយ្យភាពនៃការផ្តល់សេវាសាធារណៈផងដែរ។ នៅពេលពួកគេដឹងអំពីនីតិវិធី និងតម្លៃនៃសេវាដែលពួកគេត្រូវការ ភាពមិនប្រក្រតី ឬអំពើពុករលួយនឹងត្រូវបានកាត់បន្ថយ។ តាមរយៈការបើកចំហព័ត៌មាន និងទិន្នន័យ ប្រជាពលរដ្ឋចាប់ផ្តើមមានទំនុកចិត្តលើរដ្ឋាភិបាលកាន់តែខ្លាំង និងចូលរួមកិច្ចការនានា ដើម្បីបង្កើនអភិបាលកិច្ចសេវាសាធារណៈដោយការរាយការណ៍នូវមតិត្រឡប់ ចំណុចខ្វះខាត ឬសំណើផ្សេងៗ ហើយចាប់ផ្តើមហ៊ានប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការសួរនាំ ឬបញ្ចេញទស្សនៈដោយមានភស្តុតាងទៅលើការអនុវត្តការងារ ឬការចំណាយថវិកាសាធារណៈជាដើម ដែលនឹងធ្វើឱ្យរដ្ឋាភិបាលកាន់តែមានគណនេយ្យភាព។

ចំពោះរដ្ឋាភិបាលវិញ ព័ត៌មាន និងទិន្នន័យបើកទូលាយដើរតួនាទីជាធាតុចូល ដើម្បីឱ្យរដ្ឋាភិបាលដឹងពីបញ្ហាអាទិភាពថ្នាក់ជាតិ ថ្នាក់មូលដ្ឋាន និងជាសូចនាករដ៏ចាំបាច់សម្រាប់វាស់វែងពីការអភិវឌ្ឍលើគ្រប់វិស័យ។ ការមានព័ត៌មាន ឬទិន្នន័យអំពីតម្រូវការរបស់ប្រជាពលរដ្ឋចំពោះសេវាសាធារណៈ របាយការណ៍ហិរញ្ញវត្ថុនៃ សេវាសាធារណៈនីមួយៗ ឬការផ្តល់សេវាសាធារណៈនៅតាមប្រទេសជិតខាង ជួយឱ្យរដ្ឋាភិបាលមានទិន្នន័យគ្រប់ជ្រុងជ្រោយក្នុងសេចក្តីសម្រេចសំខាន់ៗ ឬការអនុម័តគោលនយោបាយដ៏ត្រឹមត្រូវ និងទាន់ពេលវេលា ដូចជាការវិភាគថវិកាប្រចាំឆ្នាំ ឬការចាត់អាទិភាពសេវាសាធារណៈណាមួយ។ ឧទាហរណ៍៖ ការសម្រេចបង្កើតសេវាចុះបញ្ជីពន្ធដារតាមអ៊ីនធឺណិត ការដាក់ឱ្យដំណើរការរថយន្តក្រុងសាធារណៈបន្ថែម។ ព័ត៌មាន និងទិន្នន័យបើកទូលាយជួយរដ្ឋាភិបាល ឱ្យធានាបាននូវកម្រិតប្រកួតប្រជែងស្មើភាពរវាងក្រុមហ៊ុនម៉ៅការទាំងអស់ ដែលចូលរួមដេញថ្លៃផ្គត់ផ្គង់សេវាសាធារណៈឱ្យរដ្ឋាភិបាល ថែមទាំងធានាគុណភាពសេវាសាធារណៈនិងប្រសិទ្ធភាពនៃការចំនាយថវិកាជាតិ។ តម្លាភាព និងគណនេយ្យភាពក្នុងលទ្ធកម្មសាធារណៈ(ហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារ និងថ្នាំពេទ្យ។ល។) គឺជាប្រធានបទដ៏សំខាន់ក្នុងការពិភាក្សា។ វាក៏ជួយឱ្យរដ្ឋាភិបាល មានប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងកាន់តែប្រសើរតាមរយៈការធ្វើអធិការកិច្ច និងសវនកម្មលើព័ត៌មាន និងទិន្នន័យដែលមានស្រាប់ផងដែរ។ ជាលទ្ធផល មន្ត្រីរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ បំពេញភារកិច្ចតាមវិជ្ជាជីវៈរបស់ខ្លួនកាត់បន្ថយការអនុវត្តខុសឆ្គងក្នុងស្ថាប័នរដ្ឋបង្កើនចំណូលថវិកាជាតិ ហើយចុងក្រោយគឺបង្កើនអភិបាលកិច្ចសេវាសាធារណៈ។ មិនតែប៉ុណ្ណោះ ការបើកចំហព័ត៌មាន និងទិន្នន័យជួយឱ្យជំនឿទុកចិត្ត រវាងរដ្ឋាភិបាល និងសហគមន៍អន្តរជាតិ ប្រទេសម្ចាស់ជំនួយ ដៃគូអភិវឌ្ឍន៍ និងប្រជាពលរដ្ឋកាន់តែប្រសើរឡើង ដែលរួមចំណែកក្នុងការបង្កើនវិនិយោគទុនបរទេស ជំនួយអភិវឌ្ឍន៍លើអភិបាលកិច្ចសេវាសាធារណៈ ឬការទទួលបាន របបអនុគ្រោះពន្ធនាំចេញបន្ថែម។

ដោយឡែក សម្រាប់សង្គមស៊ីវិល អ្នកស្រាវជ្រាវ អ្នកសារព័ត៌មាន ប្រព័ន្ធផ្សព្វផ្សាយ វិស័យឯកជន និងភាគីពាក់ព័ន្ធ ព័ត៌មាននិងទិន្នន័យបើកទូលាយជួយឱ្យពួកគេដើរតួនាទីកាន់តែមានអត្ថន័យក្នុងការគាំទ្រ និងសហការជាមួយរដ្ឋាភិបាលដើម្បីលើកកម្ពស់គណនេយ្យភាព និងតម្លាភាពនៃការផ្តល់សេវាសាធារណៈ។ តាមរយៈការប្រើប្រាស់ ចងក្រង ឬវិភាគស៊ីជម្រៅលើព័ត៌មាន និងទិន្នន័យបើកទូលាយ តួអង្គទាំងនោះ ពិសេសសង្គម ស៊ីវិល និងអ្នកស្រាវជ្រាវអាចស្វែងរកនូវបញ្ហាប្រឈម មូលហេតុព្រមទាំងដំណោះស្រាយ ឬគោលនយោបាយថ្មីៗជុំវិញតម្លាភាព និងគណនេយ្យភាពសេវាសាធារណៈ ហើយផ្សព្វផ្សាយទៅដៃគូពាក់ព័ន្ធ។ ពួកគេក៏អាចបង្កើត និងអនុវត្តកម្មវិធីគាំទ្ររដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហាជាក់លាក់ដែលបានរកឃើញពីការវិភាគ ថែមទាំងអាចប្រើប្រាស់ លទ្ធផលស្រាវជ្រាវ ក្នុងការតស៊ូមតិទៅរដ្ឋាភិបាលដើម្បីឱ្យមានការកែលម្អ។ ឧទាហរណ៍៖ សារៈសំខាន់នៃការបង្កើត សេវាពិនិត្យសុខភាពប្រចាំខែនៅនឹងកន្លែងការងារសម្រាប់កម្មកររោងចក្រ។ អ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ដើរតួនាទីជាអ្នកបញ្ជូនសារដ៏មានប្រសិទ្ធភាពនូវព័ត៌មាន ឬទិន្នន័យជុំវិញអភិបាលកិច្ចសេវាសាធារណៈទៅកាន់សាធារណជន និងភាគីពាក់ព័ន្ធ ហើយបង្កើតឱ្យមានកិច្ចពិភាក្សា និងស្វែងរកដំណោះស្រាយភ្លាមៗ។ តួអង្គខាងលើក៏ដើរតួនាទីជួយបំប្លែងទិន្នន័យ និងព័ត៌មានដើម្បីឱ្យងាយស្រួលយល់សម្រាប់ក្រុមជនងាយរងគ្រោះ ឬក្រុមភាគតិចផងដែរ រួមមាន៖ ស្ត្រី កុមារ ជនពិការ អនក្ខរជនជាដើម។ តួអង្គទាំងអស់ខាងលើ ក៏ដើរតួនាទីជាកញ្ចក់ឆ្លុះពីការអនុវត្តការងារអភិបាលកិច្ចសេវាសាធារណៈ របស់រដ្ឋាភិបាលបានផងដែរ តាមរយៈការផ្ទៀងផ្ទាត់ព័ត៌មាន និងទិន្នន័យរបស់រដ្ឋាភិបាល ជាមួយនិងប្រភពទិន្នន័យទុកចិត្តផ្សេងទៀតដើម្បីស្វែងរកភាពមិនប្រក្រតី។ ឧទាហរណ៍ ករណីរកឃើញភាពខុសគ្នាប្រមាណទឹកប្រាក់៧៥០លានដុល្លារអាមេរិក រវាងកំណត់ត្រារបស់រដ្ឋាភិបាលកម្ពុជា ស្តីពីការនាំចេញខ្សាច់ទៅសិង្ហបុរី ធៀបនិងកំណត់ត្រារបស់សិង្ហបុរីដែលនាំចូលខ្សាច់ពីកម្ពុជា រួមទាំងទិន្នន័យរបស់ភ្នាក់ងារអង្គការសហប្រជាជាតិ។[5]

បន្ទាប់ពីការស្វែងយល់តួនាទីរបស់ព័ត៌មាន និងទិន្នន័យបើកទូលាយក្នុងការលើកកម្ពស់តម្លាភាព និងគណនេយ្យភាពសេវាសាធារណៈ យើងនឹងបន្តក្រឡេកមើលបរិបទប្រទេសកម្ពុជានាពេលបច្ចុប្បន្នជុំវិញប្រធានបទនេះ។ រាជរដ្ឋាភិបាលកម្ពុជាបាននិងបន្តប្តេជ្ញាចិត្តពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈជាពិសេសកំណែទម្រង់ប្រសិទ្ធភាពសេវាសាធារណៈរួមមាន៖ បង្កើនការផ្សព្វផ្សាយជាសាធារណៈ នូវព័ត៌មានបច្ចុប្បន្នភាពស្តីពីសេវាសាធារណៈ និងឯកសារគោលផ្សេងៗ ជំរុញការអនុវត្តយន្តការទទួលព័ត៌មានត្រឡប់ និងដោះស្រាយបណ្តឹងរបស់អ្នកទទួលសេវា ហើយនឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣។ បើទោះជាកម្ពុជា មានឯកសារគតិយុត្តមួយចំនួនចែងអំពីសិទ្ធិប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មានស្តីពី ការអភិវឌ្ឍមូលដ្ឋាន និងកាតព្វកិច្ចរបស់អាជ្ញាធរក្នុងការផ្សព្វផ្សាយព័ត៌មាន ច្បាប់ទាំងនោះមិនទាន់ត្រូវបានមើលឃើញថាមានភាពគ្រប់គ្រាន់នៅឡើយទេ។ កម្ពុជាបានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ចាប់តាំងឆ្នាំ២០១៥ ប៉ុន្តែមិនទាន់ទទួលបានការអនុម័តឱ្យប្រើប្រាស់។ យោងតាមរបាយការណ៍របស់អង្គការឃ្លាំមើលទិន្នន័យបើកទូលាយសម្រាប់ឆ្នាំ ២០១៨/២០១៩ ប្រទេសកម្ពុជាទទួលបានពិន្ទុ២៦/១០០ និងជាប់ចំណាត់ថ្នាក់១៥៤

ក្នុងចំណោមប្រទេសសរុប ១៧៨ ដែលត្រូវបានដាក់បញ្ចូលក្នុងការវាយតម្លៃអំពី ស្ថានភាពទិន្នន័យបើកទូលាយ។[6] យន្តការចងក្រង ផ្សព្វផ្សាយ រក្សាទុក និងធ្វើបច្ចុប្បន្នភាពព័ត៌មាន ឬទិន្នន័យបើកទូលាយអំពីសេវាសាធារណៈក្នុងប្រទេសកម្ពុជានៅមានកម្រិត។ ប្រទេសកម្ពុជារួមទាំងប្រទេសភាគច្រើន ក្នុងតំបន់អាស៊ីអាគ្នេយ៍ មិនទាន់មាន គេហទំព័រទិន្នន័យបើកទូលាយថ្នាក់ជាតិ លើកលែងតែប្រទេសសិង្ហបុរី ឥណ្ឌូណេស៊ី និងហ្វីលីពីន។[7] កម្ពុជាទៀតសោតក៏មិនទាន់បានចូលជាសមាជិក "ភាពជាដៃគូរដ្ឋាភិបាលបើកទូលាយ OGP"។ សម្រាប់កម្ពុជា ការយល់ដឹងពីទិន្នន័យបើកទូលាយ ព្រមទាំងវិស័យបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង គឺនៅមានភាពក្មេងខ្ចី។ ត្បិតរដ្ឋាភិបាលបញ្ចេញព័ត៌មានសាធារណៈប្រសើរជាងមុន ប៉ុន្តែទិន្នន័យបើកទូលាយអំពីព័ត៌មានសាធារណៈនៅមានកម្រិតតិចតួចបំផុត។ បច្ចុប្បន្នយើងឃើញមានតែ អង្គការទិន្នន័យអំពីការអភិវឌ្ឍ ដែលធ្វើការងារគួរឱ្យកត់សម្គាល់ជុំវិញព័ត៌មាន និងទិន្នន័យបើកទូលាយអំពីព័ត៌មានសាធារណៈនៅកម្ពុជា។ បើពិនិត្យមើលស្ថានភាពប្រជាពលរដ្ឋកម្ពុជាវិញ ស្ទើរតែទាំងអស់ (៩៩.៩%)និយាយថា ពួកគេមិនដែលបានឃើញឯកសារស្តីពីថវិកាដែលរៀបចំដោយរដ្ឋាភិបាល ហើយប្រមាណ ៩៨.៩% មិនដែលព្យាយាមស្វែងរកព័ត៌មានអំពីថវិកាជាតិឡើយ នេះបើតាមលទ្ធផលនៃការស្ទង់មតិថ្នាក់ជាតិរបស់អង្គការតម្លាភាពកម្ពុជាឆ្នាំ ២០១៨។[8] ផ្អែកលើរបាយការណ៍របស់វិទ្យាស្ថានបើកទូលាយដែលចេញផ្សាយចុងក្រោយក្នុងឆ្នាំ២០១៦[9]ប្រជាជនកម្ពុជាប្រហែល ៩៦% មានទូរសព្ទប្រើប្រាស់ ហើយជិតពាក់កណ្តាល (៤៨%) ជាប្រភេទទូរសព្ទវៃឆ្លាត។ ការស្ទង់មតិនេះរកឃើញផងដែរថា អ៊ីនធឺណិត ឬបណ្តាញសង្គមហ្វេសប៊ុកបានក្លាយជាប្រភពដ៏សំខាន់បំផុតសម្រាប់ប្រជាជនកម្ពុជាក្នុងការទទួលបានព័ត៌មាន។

ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមនាពេលបច្ចុប្បន្ន និងឈានទៅសម្រេចបាននូវ គោលដៅលើកកម្ពស់អភិបាលកិច្ចសេវាសាធារណៈ រាជរដ្ឋាភិបាលកម្ពុជាគួរប្រឹងប្រែងឱ្យកាន់តែខ្លាំងបន្ថែមទៀត ក្នុងការទាញយកប្រយោជន៍ពី ព័ត៌មាន និងទិន្នន័យបើកទូលាយ។ ការពន្លឿនការអនុម័ត និងការអនុវត្តឱ្យមានប្រសិទ្ធភាពនូវបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលព័ត៌មាន គឺជាជំហានដំបូង។ ការបញ្ចេញ រក្សាទុក និងធ្វើបច្ចុប្បន្នភាពព័ត៌មានសាធារណៈឱ្យកាន់តែទូលំទូលាយលើគ្រប់វិស័យ ហើយរៀបចំទៅតាមទម្រង់ ដែលងាយស្រួលយល់ចំពោះមនុស្សភាគច្រើន គឺជាការងារស្នូល។ រដ្ឋាភិបាលគួរពិចារណា បង្កើតគេហទំព័រទិន្នន័យបើកទូលាយថ្នាក់ជាតិ ដើម្បីប្រមូលផ្តុំទិន្នន័យសាធារណៈទាំងអស់នៅមួយកន្លែង ដែលសាធារណជនងាយស្រួលស្វែងរក ពេលពួកគេត្រូវការ។ ការងារនេះអាចចាប់ផ្តើមដោយអនុវត្តឧបករណ៍វាយតម្លៃស្តីពីការត្រៀមខ្លួនរបស់រាជរដ្ឋាភិបាលសម្រាប់ទិន្នន័យបើកទូលាយ (Open Data Readiness Assessment) ដែលត្រូវបានរៀបចំដោយធនាគារពិភពលោក។[10] ការបង្ហាញព័ត៌មាន និងទិន្នន័យទៅតាមទម្រង់ងាយស្រួលយល់សម្រាប់ក្រុមមនុស្សផ្សេងៗ ពោលគឺទម្រង់ទិន្នន័យអន្តរកម្ម(Interactive data) ដូចជា៖ ការប្រើប្រាស់ផែនទីភូមិសាស្ត្រ (GIS) ទស្សនីយភាពទិន្នន័យ (Data visualization)។ល។ ហើយនិងទម្រង់ផ្សេងទៀតរួមមាន៖ ក្រាហ្វិកព័ត៌មាន ឯកសារសំឡេង វីដេអូជាដើម។ រដ្ឋាភិបាលក៏ត្រូវយកចិត្តទុកដាក់ផងដែរនូវការប្រមូលព័ត៌មានត្រឡប់ពីអ្នកប្រើប្រាស់សេវាសាធារណៈ។ ដូចគ្នាដែរ ប្រជាពលរដ្ឋ និងស្ថាប័នពាក់ព័ន្ធ រួមមាន៖ សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ អ្នកសារព័ត៌មាន

ប្រព័ន្ធផ្សព្វផ្សាយ ឬវិស័យឯកជនគួរប្រតិបត្តិការការងារប្រចាំថ្ងៃទៅតាមជំនាញ និងបេសកកម្មរបស់ខ្លួនដើម្បីគាំទ្ររដ្ឋាភិបាលក្នុងការលើកកម្ពស់តម្លាភាពនិងគណនេយ្យភាពនៃការផ្តល់សេវាសាធារណៈ តាមរយៈការពង្រឹងវិសាលភាពព័ត៌មាន និងទិន្នន័យបើកទូលាយអំពីសេវាសាធារណៈ និងកិច្ចការងារផ្សេងៗទៀត។

ជារួមមក ព័ត៌មាន និងទិន្នន័យបើកទូលាយដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់តម្លាភាព និងគណនេយ្យភាពនៃការផ្តល់សេវាសាធារណៈ។ ហើយប្រទេសកម្ពុជានៅមានការងារច្រើនទៀតត្រូវធ្វើ ដើម្បីលើកកម្ពស់អភិបាលកិច្ចសេវាសាធារណៈរបស់ខ្លួន។ ការវិនិយោគលើ ព័ត៌មាន និងទិន្នន័យបើកទូលាយអំពីសេវាសាធារណៈ គឺជាជម្រើសដ៏ល្អប្រសើរដែលនឹងនាំយកផលប្រយោជន៍ឥតគណនា ចំពោះការអភិវឌ្ឍប្រកបដោយចីរភាព និងជានាកម្រិតប្រកួតប្រជែងរបស់ខ្លួននៅលើពិភពលោក។ ធនាគារពិភពលោកបានចងក្រងករណីសិក្សានៅប្រទេសជាច្រើន ដែលបង្ហាញពីភាពជោគជ័យក្នុងការងារនេះ រួមទាំងប្រទេសកំពុងអភិវឌ្ឍដែលមានបរិបទស្រដៀងកម្ពុជាទៀតផង។[11] យ៉ាងណាក៏ដោយ ការ ងារនេះមិនអាចសម្រេចទៅបាន ដោយសារតែកិច្ចខំប្រឹងប្រែងរបស់រដ្ឋាភិបាលម្ខាងនោះទេ ការរួមចំណែកពីភាគីពាក់ព័ន្ធក៏មានសារៈសំខាន់ដូចគ្នា។

តាមរយៈអត្ថបទនេះ លោកអ្នកនឹងទទួលបានព័ត៌មាន ព្រមទាំងចំណេះដឹងដែលបកស្រាយនូវចម្ងល់ខាងលើ៕

# ឯកសារពិគ្រោះយោបល់

---

[1] *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ នីតិកាលទី៦*, ២០១៨, រដ្ឋាភិបាលកម្ពុជា, https://moicms.interior.gov.kh/view/file/1542165686.pdf

[2] *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣*, ២០១៩, រដ្ឋាភិបាលកម្ពុជា, https://www.moeys.gov.kh/index.php/kh/policies-and-strategies/3179.html

[3] *គេហទំព័រអង្គការទិន្នន័យអំពីការអភិវឌ្ឍ (ODC)*, https://opendevelopmentcambodia.net/km/

[4] *What is Open Data?*, Open Knowledge Foundation, https://opendatahandbook.org/guide/en/what-is-open-data/

[5] *Alex Willemyns and Mech Dara: Singapore's data mirrors UN's on Cambodia's sand export numbers*, ២០១៦, កាសែតភ្នំពេញប៉ុស្តិ៍, https://www.phnompenhpost.com/national/singapores-data-mirrors-uns-cambodias-sand-export-numbers

[6] *The 2018/19 Open Data Inventory (ODIN)*, 2019, Open Data Watch, http://odin.opendatawatch.com/report/pressReport

[7] *National open data platform*, Data.gov, https://www.data.gov/open-gov/

[8] *Drs Sabina Lawreniuk & Laurie Parsons: គណនេយ្យភាព និងតម្លាភាពនៃដំណើរការថវិកា*, ២០១៨, អង្គការតម្លាភាពកម្ពុជា, http://ticambodia.org/library/

[9] *ការស្ទង់មតិអំពីការប្រើប្រាស់ទូរសព្ទដៃ និងអ៊ីនធឺណិតនៅកម្ពុជា*, ២០១៦, វិទ្យាស្ថានបើកទូលាយ, https://open.org.kh/en/reports

[10] *Open Data Readiness Assessment (ODRA)*, World Bank, http://opendatatoolkit.worldbank.org/en/odra.html

[11] Open Data for Sustainable Development, 2015, World Bank, http://pubdocs.worldbank.org/en/741081441230716917/Open-Data-for-Sustainable-development-PN-FINAL-ONLINE-September1.pdf

*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០២០*

# "តួនាទីនៃទិន្នន័យបើកទូលាយ និងព័ត៌មានក្នុងការលើកកម្ពស់តម្លាភាព និងគណនេយ្យភាព ក្នុងការផ្តល់សេវាសាធារណៈនៅកម្ពុជា"

សែម ពិសី*

ជ័យលាភីលេខ៣ ការប្រកួតសំណេរទិវាទិន្នន័យបើកទូលាយឆ្នាំ ២០២០

## សេចក្តីផ្តើម

មួយទសវត្សរ៍ចុងក្រោយនេះ កម្ពុជាបានក្លាយជាប្រទេស មានសន្ទុះសេដ្ឋកិច្ចរីកចម្រើនយ៉ាងឆាប់រហ័សស្មើរគ្រប់វិស័យនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ យោងតាមការព្យាករណ៍ពីសំណាក់ ស្ថាប័នអន្តរជាតិធំៗ ចំនួន៣ គឺធនាគារ អភិវឌ្ឍន៍អាស៊ី ធនាគារ ពិភពលោក និងស្ថាប័នរូបិយវត្ថុអន្តរជាតិ ឆ្នាំ២០១៩ ដោយបានព្យាករពីកំណើនសេដ្ឋកិច្ចរបស់កម្ពុជាថា នៅតែរក្សាបានក្នុងកំណើន ៧% តួរលេខនេះបង្ហាញថា រាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តគោលនយោបាយសេដ្ឋកិច្ចនិងពាណិជ្ជកម្មល្អប្រសើរព្រមទាំងជំរុញស្មើគ្រប់វិស័យទាំងអស់ ឲ្យមានសន្ទុះខ្លាំងក្លាក្នុងការលើកកម្ពស់តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈនៅកម្ពុជាជាដើម។

ខណៈដែលប្រទេសកម្ពុជា បន្តការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមដោយរក្សាបានកំណើនគួរឲ្យកោតសរសើរនេះ កម្ពុជាក៏កំពុងខិតខំប្រឹងប្រែងប្រកួតប្រជែងសេដ្ឋកិច្ច និងពាណិជ្ជកម្មទាំងក្នុងក្របខណ្ឌតំបន់ និងកសាងខឿនសេដ្ឋកិច្ចរបស់ខ្លួនឲ្យរឹងមាំ ដោយទាមទារសក្តានុពលធនធនធានមនុស្ស កម្លាំងពលកម្ម ព្រមទាំងគំនិតច្នៃប្រឌិតថ្មីៗ ឬនវានុវត្តន៍ក្នុងការប្រើប្រាស់ទន្និន័យបើកទូលាយ និងព័ត៌មានចាំបាច់បំផុត។ ទន្និន័យបើកទូលាយ និងព័ត៌មាននេះ ប្រជាពលរដ្ឋ ពិសេសយុវជនកម្ពុជា នឹងក្លាយជាចលករសំខាន់បំផុត ដែលត្រូវត្រៀមខ្លួនដើរតាមព័ត៌មាន ប្រើប្រាស់ព័ត៌មាន និងចូលរួមបង្កើតគំនិតថ្មីៗក្នុងការប្រើប្រាស់ទន្និន័យ និងព័ត៌មាន ក្នុងការរួមចំណែកលើកកម្ពស់តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈនៅកម្ពុជា។

ប៉ុន្តែទោះជាយ៉ាងណា ការគិតគូរដល់តួនាទីនៃទិន្នន័យបើកទូលាយ និងព័ត៌មានក្នុងការលើកកម្ពស់តម្លាភាពនិងគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈនៅកម្ពុជានេះ ត្រូវមានការចូលរួម ពីតួអង្គបីសំខាន់ៗក្នុងដំណើរដ៏វែងឆ្ងាយទៅអនាគតកាលខាងមុខ ក្នុងនោះមានប្រជាពលរដ្ឋកម្ពុជា វិស័យឯកជននៅកម្ពុជា ព្រមទាំងតួអង្គរដ្ឋាភិបាលកម្ពុជា។

## ហេតុអ្វីត្រូវនិយាយដល់តួនាទីនៃទិន្នន័យបើកទូលាយ និងព័ត៌មាន?

ខណៈដែលប្រទេសកម្ពុជាបន្តការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមដោយរក្សាបានកំណើនគួរឲ្យកត់សម្គាល់នេះ និងស្របពេលបច្ចុប្បន្នការវិនិយោគបរទេសនានានៅកម្ពុជាកំពុងមានការរីកលូតលាស់ឥតឈប់ឈរ។ យ៉ាង

---

* **សែម ពិសី** បច្ចុប្បន្ននាងជាអ្នកសារព័ត៌មានឯករាជ្យ (Freelancer)។

(រក្សាសិទ្ធិអត្ថបទដោយស្មេរ សែម ពិសី និងកម្មវិធីការប្រកួតប្រជែងសំណេរយុវជនសម្រាប់ព្រឹត្តិការណ៍ទិន្នន័យបើកទូលាយ ២០២០)